ព្រឹត្តិបត្រព័ត៌មាន

NEC BULLETIN


# គ.ជ.ប

## ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣

## ថ្ងៃអាទិត្យ ទី០៣ ខែមិថុនា ឆ្នាំ២០១២


លេខ ០៩ ចេញផ្សាយថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១២




ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## មាតិកា


- ស្ថាប័នពាក់ព័ន្ធនឹងការបោះឆ្នោតជាច្រើនវាយតម្លៃល្អ............. ២
- សរុបបណ្តឹងក្នុងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា.... ៦
- សន្និបាតបូកសរុបការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា....... ១៣
- ប្រតិទិននៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត........ ១៥





www.necelect.org.kh, www.voterlist.org.kh, Email: necinfo@forum.org.kh, Phone/Fax (023) 214 374

# ស្ថាប័នពាក់ព័ន្ធនឹងការបោះឆ្នោតជាច្រើន វាយតម្លៃល្អអំពីការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តទី៣



លទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ នាថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១២ ត្រូវបានប្រកាសនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១២ ។

គណបក្សនយោបាយចំនួន ៧ ក្នុងចំណោមគណបក្សទាំង ១០ ដែលចូលរួមប្រកួតប្រជែងការបោះឆ្នោតនេះបានជាប់ឆ្នោត និងទទួលអាសនៈក្នុងឃុំសង្កាត់ ។

លទ្ធផលផ្លូវការនៃការបោះឆ្នោតនេះ ត្រូវបានគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយ មជ្ឈដ្ឋានជាតិ អន្តរជាតិ និងស្ថាប័នពាក់ព័ន្ធនឹងការបោះឆ្នោតនានា បានចេញសេចក្តីថ្លែងការណ៍ជាបន្តបន្ទាប់គាំទ្រ និងវាយតម្លៃថា ដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១២នេះ បានប្រព្រឹត្តទៅដោយរលូន គ្មានអំពើហិង្សា គ្មានការគំរាមកំហែង ប្រកបដោយតម្លាភាព សេរី ត្រឹមត្រូវ និងយុត្តិធម៌ ហើយលទ្ធផលនៃការបោះឆ្នោតនេះទៀតសោត បានឆ្លុះបញ្ចាំងពីឆន្ទៈរបស់ប្រជាពលរដ្ឋអ្នកបោះឆ្នោត ។

ស្ថាប័នដែលចេញសេចក្តីថ្លែងការណ៍គាំទ្រការបោះឆ្នោតនេះមានដូចខាងក្រោម ៖

នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២ លោក សោម អូន ប្រធានក្រុមប្រឹក្សាសហជីពជាតិកម្ពុជា(CCNU) បានចេញសេចក្តីថ្លែងការណ៍គាំទ្រចំពោះលទ្ធផលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិនេះ(តាមគេហទំព័រ CEN ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២) ។

សេចក្តីថ្លែងការណ៍របស់ CCNU បានបង្ហាញថា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១២ ដែលរៀបចំដោយ គ.ជ.ប នាពេលកន្លងមកនេះ ពិតជាបានប្រព្រឹត្តទៅយ៉ាងរលូន សេរី ត្រឹមត្រូវ យុត្តិធម៌ តម្លាភាព និងគ្មានអំពើហិង្សា ។ សេចក្តីថ្លែងការណ៍បានបន្តថា ប្រជាពលរដ្ឋទាំងពីរភេទ បានបំពេញកាតព្វកិច្ចរបស់ខ្លួនស្របតាមច្បាប់រដ្ឋធម្មនុញ្ញ ដោយអញ្ជើញទៅចូលរួមបោះឆ្នោតយ៉ាងច្រើនកុះករ ប្រកបដោយទឹកមុខរីករាយ ពុំមានការបង្ខិតបង្ខំ បំភិតបំភ័យ ជ្រៀតជ្រែក និងការគំរាមកំហែងពីមជ្ឈដ្ឋាន ឬគណបក្សនយោបាយណាមួយឡើយ ។

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL) បានចេញសេចក្តីថ្លែងការណ៍កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ ថា ការ



សកម្មភាពរាប់សន្លឹកឆ្នោតនៅការិយាល័យរាប់សន្លឹកឆ្នោតមួយក្នុងខេត្តព្រៃវែង កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១២ កន្លងមក

ប្រព្រឹត្តទៅ និងការចាត់ចែងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិថ្មីនេះ ពុំមានអំពើហិង្សា និងភាពមិនប្រក្រតីធ្ងន់ធ្ងររហូតធ្វើឲ្យរាំងស្ទះដល់ដំណើរការបោះឆ្នោតទេ ។ សេចក្ដីថ្លែងការណ៍នោះក៏បានសរសើរ គ.ជ.ប ថា "**ការចាត់ចែង និងការគ្រប់គ្រងការបោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានជានាភាពសម្ងាត់ការបោះឆ្នោត និងភាពរលូននៅថ្ងៃបោះឆ្នោត**" ។

រីឯក្រុមកែវភ្នែកយុត្តិធម៌ ដែលជាក្រុមអង្គការមិនមែនរដ្ឋាភិបាល ក៏បានចាត់ទុកការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិនេះថា បានប្រព្រឹត្តទៅដោយរលូន មានភាពល្អប្រសើរជាងអាណត្តិមុនៗ (យោងតាមអត្ថបទសារព័ត៌មានរស្មីកម្ពុជា ចេញផ្សាយថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១២)។ ក្រុមនេះបានវាយតម្លៃថា "**លទ្ធផលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២ អាចទុកចិត្ត និងយកជាការបាន**" ។

ក្រុមកែវភ្នែកយុត្តិធម៌បានអះអាងថា អ្នកបោះឆ្នោតពិតជាបានបោះឆ្នោតតាមឆន្ទៈរបស់ខ្លួនពិតប្រាកដមែន គ្មានសញ្ញាណាមួយដែលបញ្ជាក់ថា មានការបង្ខិតបង្ខំ ឬបំភិតបំភ័យ និងការទិញទឹកចិត្តអ្នកបោះឆ្នោតទាំងនោះទេ ។ ការបោះឆ្នោតមានលក្ខណៈសម្ងាត់ ព្រោះបន្ទប់សម្ងាត់(សម្រាប់អ្នកបោះឆ្នោតចូលគូសសន្លឹកឆ្នោត) បានបិទបាំងជិត មិនមានមនុស្សដើរឆ្លងកាត់ ។

គណៈកម្មាធិការសំរបសំរួលខ្មែរកម្ពុជាក្រោម ដែលមានអង្គការ សមាគមចំនួន ៧ ជាសមាជិក និងជាអង្គការមិនមែនរដ្ឋាភិបាលជាតិ ដែលបានចូលរួមពិនិត្យ និងសង្កេតមើលដំណើរការបោះឆ្នោតនេះ បានចេញសេចក្ដីថ្លែងការណ៍មួយ កាលពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១២ ដែលប្រកាសទទួលយកលទ្ធផលបឋមនៃការ





សកម្មភាពដឹកជញ្ជូនសម្ភារបោះឆ្នោតពី គឃ/សប ទៅ គកប/គករ នៅខេត្តមណ្ឌលគិរី

បោះឆ្នោតនាថ្ងៃទី០៣ ខែមិថុនា កន្លងមកនោះ ។ សេចក្ដីថ្លែងការណ៍នោះបានបញ្ជាក់ថា "**គណៈកម្មាធិការយើងខ្ញុំបានតាមដានយ៉ាងយកចិត្តទុកដាក់ចាប់ពីថ្ងៃឃោសនារកសម្លេងឆ្នោត ថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត យើងបានពិនិត្យស្ទើរតែគ្រប់ចំណុចសំខាន់ៗ**" ។ សេចក្ដីថ្លែងការណ៍ដដែលនេះក៏បានឲ្យដឹងទៀតថា ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតបានចូលរួមបោះឆ្នោតដោយសេរី តាមឆន្ទៈ គ្មានការរារាំង រើសអើង ប្រកាន់និន្នាការនយោបាយ និងគ្មានការបង្កភាពស្មុគស្មាញឡើយ ។

រីឯគណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ដើម្បីបោះឆ្នោត ក៏បានចេញសេចក្ដីថ្លែងការណ៍មួយ ក្រោយថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ មួយថ្ងៃ ពោលគឺថ្ងៃទី០៤ ខែមិថុនា ដោយបានថ្លែងថា ផ្អែកលើរបាយការណ៍ទទួលបានពីឃុំ សង្កាត់ តាមគោលដៅ អង្គការខ្លួនបានរកឃើញថា បរិយាកាសទូទៅនៃការបោះឆ្នោតភាគច្រើនមានសណ្ដាប់ធ្នាប់ គ្មានឧបសគ្គ និងអំពើហិង្សា បើទោះបីមានការអាក់អួលខ្លះៗនៅតាមការិយាល័យបោះឆ្នោតមួយចំនួននៅរាជធានីភ្នំពេញ និងខេត្តឧត្តរមានជ័យ ដោយសារអាកាសធាតុមិនល្អក៏ដោយ ។



សកម្មភាពបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ក្នុងការិយាល័យបោះឆ្នោត នៅខេត្តពោធិ៍សាត់



សកម្មភាពត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៅ គខប កំពង់ឆ្នាំង

ការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា ហៅកាត់ថា NICFEC ដែលបានដាក់អ្នកសង្កេតការណ៍បោះឆ្នោតចំនួន ១.៩៤៦នាក់ ដើម្បីសង្កេតមើលដំណើរការ

ក៏មិនខុសពីការលើកឡើងរបស់មជ្ឈដ្ឋាននានានៅក្នុងប្រទេសកម្ពុជា ប្រមុខការទូតនានាមកពីប្រទេសដែលប្រកាន់ភ្ជាប់នូវលទ្ធិប្រជាធិបតេយ្យយ៉ាងរឹងមាំមួយ





សកម្មភាពត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ នៅ គខប ស្វាយរៀង កាលពីថ្ងៃទី០៥ ខែមិថុនា

ចំនួន ក៏បានសាទរ និងសរសើរអំពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ក៏ដូចជាការរីកចម្រើននៃលិទ្ធិប្រជាធិបតេយ្យនៅកម្ពុជាផងដែរ ។

ក្នុងអំឡុងពេលដឹកនាំគណៈប្រតិភូចូលជួបសម្ដែងការគួរសមជាមួយសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅវិមានសន្តិភាពកាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១២ លោក ហ៊ឺមិន អូតូ ស៊ុម ( Hermann otto Solms ) អនុប្រធានសភាសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ បានមានប្រសាសន៍ថា លោកបានទៅធ្វើទស្សនកិច្ចនៅកន្លែងបោះឆ្នោតចំនួន ២ និងបានពិនិត្យឃើញថា កន្លែងបោះឆ្នោតទាំងនោះមានភាពសមស្រប ហើយរូបលោកក៏សម្ដែងនូវការរីករាយចំពោះដំណើរការលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ។

នាឱកាសចូលជួបសម្ដែងការគួរសមជាមួយសម្ដេចអគ្គមហាពញាចក្រីកិត្តិព្រឹទ្ធបណ្ឌិត ហេង សំរិន ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជានៅវិមានរដ្ឋសភា កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១២ លោក វីលៀម អ៊ីធូត ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំកម្ពុជា បានវាយតម្លៃថា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ឆ្នាំនេះធ្វើឡើងក្រោមបរិយាកាសដ៏ល្អ និងសូមសរសើរចំពោះកម្ពុជា ហើយលោកនឹងធ្វើការសង្កេតតទៅទៀតចំពោះការបោះឆ្នោតសកលនាពេលខាងមុខ ។ នេះបើយោងតាមប្រសាសន៍របស់ឯកឧត្ដម គាំ កុសល ប្រធានខុទ្ទកាល័យសម្ដេចប្រធានរដ្ឋសភា ដែលបានថ្លែងប្រាប់អ្នកយកព័ត៌មានអំពីជំនួបនោះ ។

ជាមួយគ្នានេះ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ លោក ផេត្រូ សេឡាណូ ប្រធានប្រតិភូសហគមន៍អឺរ៉ុប និងជានាយកទទួលបន្ទុកសេវាកម្មក្រៅប្រទេសរបស់សហគមន៍អឺរ៉ុបប្រចាំតំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ បានមានប្រសាសន៍ថា សហគមន៍អឺរ៉ុបនឹងបន្តជួយគាំទ្រដល់កម្ពុជា ថ្វីត្បិតតែសហគមន៍អឺរ៉ុបកំពុងជួបវិបត្តិហិរញ្ញវត្ថុក៏ដោយ ហើយសហគមន៍អឺរ៉ុបសូមគាំទ្រលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់កន្លងមកនេះ គឺសំដៅលើការបោះឆ្នោតមួយដែលគ្មានអំពើហិង្សា ។ ការថ្លែងបែបនេះធ្វើឡើងនៅពេលដែលលោក ផេត្រូ សេឡាណូ ចូលជួបពិភាក្សាការងារជាមួយឯកឧត្ដម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅទីស្ដីការក្រសួងមហាផ្ទៃ ។

ការលើកឡើងខាងលើនេះ គឺជាទឡ្ហីករណ៍មួយដែលអាចបញ្ជាក់បានថា ការបោះឆ្នោតនៅកម្ពុជាបាននឹងកំពុងតែអនុវត្តបានយ៉ាងត្រឹមត្រូវតាមច្បាប់ និងតាមគោលការណ៍ប្រជាធិបតេយ្យ ស្របតាមការកំណត់របស់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ៕

# សរុបបណ្តឹងក្នុងដំណើរការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣



បណ្តឹងសរុបចំនួន ២៦៥បណ្តឹង ត្រូវបានដាក់នៅក្នុងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២ ក្នុងនោះបណ្តឹងកើតឡើងក្នុងដំណាក់កាលចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតមានចំនួន ២៩បណ្តឹង ដំណាក់កាលឃោសនាបោះឆ្នោតចំនួន ៩១បណ្តឹង នៅរយៈពេលមួយថ្ងៃមុនថ្ងៃបោះឆ្នោតចំនួន ៣បណ្តឹង និងដំណាក់កាលបោះឆ្នោត និងរាប់សន្លឹកឆ្នោតមានចំនួន ១៤២បណ្តឹង ។ បណ្តឹងទាំងអស់ត្រូវបានគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត(គឃ/សប) គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គជ/ខប) និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដោះស្រាយរួចរាល់ជាស្ថាពរ ។

សូមបញ្ជាក់ថា សម្រាប់ការបោះឆ្នោតនេះមានបណ្តឹងចំនួន ៤ ទាក់ទងនឹងការឃោសនាបោះឆ្នោត បោះឆ្នោត និងរាប់សន្លឹកឆ្នោត ត្រូវបាន គ.ជ.ប បើកសវនាការជាសាធារណៈរយៈពេល ៤ថ្ងៃជាប់ៗគ្នា គឺចាប់ពីថ្ងៃទី១៣-១៦ ខែមិថុនា ឆ្នាំ២០១២ ។

***សវនាការលើកទី១*** : ជំនុំជម្រះបណ្តឹងរបស់គណបក្ស សម រង្ស៊ី ដែលបានប្តឹងអនុប្រធានភូមិគោរដ្ឋានពីបទហៅប្រជាពលរដ្ឋចូលក្នុងផ្ទះដើម្បីឃោសនាមុនទៅបោះឆ្នោត ។ ខ្លឹមសារនៃការជំនុំជម្រះមានដូចតទៅ ៖

កាលថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១២ ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានសម្រេចបដិសេធបណ្តឹងលេខ០០៧/១២ របស់គណបក្ស សម រង្ស៊ី ដែលបានដាក់ពាក្យបណ្តឹងអនុប្រធានភូមិគោរដ្ឋាន សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ពីបទហៅប្រជាពលរដ្ឋចូលក្នុងផ្ទះរបស់គាត់ ដើម្បីឃោសនាមុនប្រជាពលរដ្ឋទៅបោះឆ្នោត។ ការសម្រេចបដិសេធនេះ បានធ្វើឡើងបន្ទាប់ពីក្រុមប្រឹក្សាជំនុំជម្រះបានលើកយកបណ្តឹងនេះមកបើកសវនាការជាសាធារណៈនៅចំពោះមុខដើមបណ្តឹង និងចុងចម្លើយ នាទីស្តីការ គ.ជ.ប ។



លោក រស់ សួរ តំណាងគណបក្ស សម រង្ស៊ី

លោក រស់ សួរ តំណាងគណបក្ស សម រង្ស៊ី ដែលទទួលបានការផ្ទេរសិទ្ធិពីលោក សួន សៀប តំណាង





គ.ជ.ប បើកសវនាការជាសាធារណៈនៅទីស្តីការរបស់ខ្លួន កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១២

គណបក្ស សម រង្ស៊ី នៅខេត្តបន្ទាយមាជ័យ បានរៀបរាប់ប្រាប់ក្រុមប្រឹក្សាជំនុំជម្រះថា លោកប្ដឹងឈ្មោះ ភិន សុខា អនុប្រធានភូមិគោរដ្ឋាន សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ពីបទហៅប្រជាពលរដ្ឋចូលក្នុងផ្ទះរបស់គាត់នៅចន្លោះពីម៉ោង ៧ :០០ ទៅម៉ោង ៧ :៣០ នាទីព្រឹក កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១២ ដើម្បីឃោសនាមុនប្រជាពលរដ្ឋទៅបោះឆ្នោត ដែលទង្វើបែបនេះវាខុសនឹងច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធី ។



លោក ភិន សុខា អនុប្រធានភូមិគោរដ្ឋាន

ក្រៅពីការរៀបរាប់ដោយផ្ទាល់មាត់ លោក រស់ សួរ មិនបានបង្ហាញភ័ស្តុតាងដល់ក្រុមប្រឹក្សាជំនុំជម្រះ ដើម្បីដាក់បន្ទុកលើចុងចម្លើយឡើយ ។

នៅក្នុងសវនាការ លោក ភិន សុខា ដែលជាអនុប្រធានភូមិ និងជាចុងចម្លើយ បានថ្លែងថា គាត់មិនបានហៅប្រជាពលរដ្ឋឱ្យចូលក្នុងផ្ទះគាត់ដើម្បីឃោសនានោះទេ ពីព្រោះគាត់យល់ពីច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធី គ.ជ.ប ថា នៅថ្ងៃទី០២-០៣ ខែមិថុនា ឆ្នាំ២០១២ ជាថ្ងៃដែលគេមិនឱ្យឃោសនា ដូច្នេះគាត់គោរពច្បាប់។ លោក សុខា បានបញ្ជាក់ថា ការដែលប្រជាពលរដ្ឋចូលផ្ទះរបស់គាត់ ពីព្រោះប្រពន្ធរបស់គាត់លក់បបរនៅក្រោមផ្ទះ ហើយប្រជាពលរដ្ឋទាំងនោះនាំគ្នាចូលទៅហូបបបរ។ លោកបានបន្ថែមថា ជាធម្មតា ប្រពន្ធរបស់គាត់លក់បបរនៅក្នុងសាលារៀន ហើយនៅថ្ងៃបោះឆ្នោតគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត( គឃ/សប) បានយកសាលារៀននោះធ្វើជាទីតាំងការិយាល័យបោះឆ្នោត ដែលធ្វើឱ្យប្រពន្ធរបស់គាត់មិនអាចលក់បាននៅក្នុងបរិវេណសាលានៅថ្ងៃនោះ ទើបគាត់មកលក់នៅក្រោមផ្ទះរបស់គាត់វិញ ។ ម្យ៉ាងទៀត ផ្ទះរបស់គាត់មានរបង និងមានទ្វារមួយអាចចូលទៅក្នុងសាលារៀននោះបាន ។ តាម

ជម្មតា ប្រជាពលរដ្ឋរស់នៅជិតខាង និងសិស្សតែងតែនាំគ្នាចេញចូលតាមច្រករបងទ្វារក្រោយរបស់គាត់ទៅសាលារៀន ។

ក្រោយពីស្តាប់ដើមបណ្តឹង និងចុងចម្លើយ និងក្រោយពីបានពិចារណាលើអង្គហេតុរួចមក ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប បានសម្រេចបដិសេធបណ្តឹងរបស់គណបក្ស សម រង្ស៊ី ព្រោះដើមបណ្តឹងពុំមានភស្តុតាងគ្រប់គ្រាន់ ហើយក្រុមប្រឹក្សាជំនុំជម្រះ គ.ជ.ប តម្កល់សេចក្តីសម្រេចរបស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តបន្ទាយមានជ័យ( គខប) ទុកជាបានការពេញទាំងមូល។ សេចក្តីសម្រេចនេះជាសេចក្តីសម្រេចចុងក្រោយ ។

សូមរំលឹកថា កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២ តំណាងគណបក្ស សម រង្ស៊ី បានដាក់ពាក្យបណ្តឹងទៅ គខប បន្ទាយមានជ័យ ប្តឹងអនុប្រធានភូមិគោរដ្ឋាន ។ ករណីនេះ គខប បន្ទាយមានជ័យ បានប្រជុំសម្រេចកាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ បដិសេធពាក្យបណ្តឹង ដោយមូលហេតុថា ពុំបានធ្វើឱ្យប៉ះពាល់ដល់ដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើយ ។ ដោយមិនសុខចិត្តនឹងសេចក្តីសម្រេចនេះ កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ លោក សួន សៀប រស់នៅភូមិព្រហូត សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ បានផ្ទេរសិទ្ធិឱ្យលោក រស់ សួរ ដើម្បីដាក់ ពាក្យបណ្តឹងបន្តមក គ.ជ.ប ។

**សវនាការលើកទី២** : ជំនុំជម្រះបណ្តឹងរបស់គណបក្ស សម រង្ស៊ី ដែលបានប្តឹងមេភូមិភ្នំដំរី មេភូមិអូរពពូល បេក្ខជនគណបក្សប្រជាជនកម្ពុជា និងក្រុមការងារគណបក្សប្រជាជនកម្ពុជា ពីបទជ្រៀតជ្រែកសិទ្ធិអ្នកបោះឆ្នោត ។ ខ្លឹមសារនៃការជំនុំជម្រះមានដូចតទៅ ៖

កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២ ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ( គ.ជ.ប) បានសម្រេចបញ្ជូនឈ្មោះ គង់ សំ មេភូមិភ្នំដំរី ឈ្មោះ ញឹម ផា មេភូមិអូរពពូល ឈ្មោះ ឌួក ឌន បេក្ខជនគណបក្សប្រជាជនកម្ពុជា ឈ្មោះ ង៉ែត ហួន និងឈ្មោះ ផេង សាលី ក្រុមការងារគណបក្សប្រជាជនកម្ពុជា ទៅក្រសួងមហាផ្ទៃដើម្បីឱ្យក្រសួងធ្វើការព្រមានតាមច្បាប់ ។ ការសម្រេចនេះ បានធ្វើឡើងបន្ទាប់ពីក្រុមប្រឹក្សាជំនុំជម្រះលើកយកបណ្តឹងលេខ ០២០/១២ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ របស់គណបក្ស សម រង្ស៊ី ដែលបានប្តឹងអ្នកទាំង៥រូបនេះថា បានជ្រៀតជ្រែកសិទ្ធិអ្នកបោះឆ្នោតនៅថ្ងៃបោះឆ្នោត កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១២ ។



លោក ហ៊ីង យឿន តំណាងគណបក្ស សម រង្ស៊ី និងជាដើមបណ្តឹង

លោក ហ៊ីង យឿន តំណាងគណបក្ស សម រង្ស៊ី ដែលបានទទួលការផ្ទេរសិទ្ធិពីឈ្មោះ ធិល អូន តំណាងគណបក្ស សម រង្ស៊ី រស់នៅភូមិអូរពពូល ឃុំដំណាក់កន្ទួតខាងជើង ស្រុកកំពង់ត្រាច ខេត្តកំពត បានរៀបរាប់ថា កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១២ ពីម៉ោង ៨ ដល់ម៉ោង ១២ ថ្ងៃត្រង់ នៅមណ្ឌលបោះឆ្នោតវត្តភ្នំដំរី មានមេភូមិ ជំនួយការភូមិ និងក្រុមការងារគណបក្សប្រជាជនកម្ពុជា ដូចមានឈ្មោះខាងលើ បានមកឈរនៅច្រកទ្វារវត្ត និងនៅក្នុងវត្តដែលជាទីតាំងការិយាល័យបោះឆ្នោត ដោយពួកគេបានទារយកឯកសារបញ្ជាក់អត្តសញ្ញាណ និងប័ណ្ណព័ត៌មាន រួចកត់ឈ្មោះ ទើបប្រគល់ឱ្យអ្នកបោះឆ្នោតវិញ ។ ទង្វើនេះគឺផ្ទុយនឹងប្រការ ៨.៨ នៃបទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើស

រើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ និងចំណុចទាំងឡាយដែលស្ថិតនៅក្រោមប្រការនេះ ដែលត្រូវផ្តន្ទាទោសតាមមាត្រា ១៣១ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

នៅក្នុងសវនាការលោក ហ៊ីង យឿន មានភស្តុតាងជារូបថតចំនួន ៦សន្លឹក ដាក់ជូនក្រុមប្រឹក្សាជំនុំជម្រះ និងសាក្សីចំនួន ២រូប ។ ឈ្មោះ នូ គីន និងឈ្មោះ ភ្លោត សុភ័ណ សាក្សីរបស់លោក ហ៊ីង យឿន បានរៀបរាប់នៅក្នុងសវនាការប្រហាក់ប្រហែលគ្នាថា ខ្លួនជាភ្នាក់ងារគណបក្ស សម រង្ស៊ី បានឃើញឈ្មោះ គង់ សំ ឈ្មោះ



លោក អ៊ួន សាកល និងលោកស្រី អ៊ិត គីហ៊ូប៉ាតី ភាគីចុងចម្លើយ

ញឹម ផា ឈ្មោះ ឌួក ឌន ឈ្មោះ ង៉ែត ហួន និងឈ្មោះ ផេង សាលី មានវត្តមាននៅទីតាំងការិយាល័យបោះឆ្នោត ហើយសុំឯកសារពីប្រជាពលរដ្ឋយកមកកត់ឈ្មោះ និងបានខ្សឹបប្រាប់អ្នកបោះឆ្នោត តែអ្នកទាំងពីរមិនបានដឹងអ្នកទាំង ៥នាក់នោះ ប្រាប់អ្នកបោះឆ្នោតពីរឿងអ្វីទេ ។



អ្នកចូលរួមស្តាប់ក្នុងអង្គសវនាការ គ.ជ.ប



ឯកឧត្តម អ៊ឹម សួស្តី ប្រធានក្រុមប្រឹក្សាជំនុំជម្រះ គ.ជ.ប

លោកស្រី អ៊ិត គីហ៊ូប៉ាតី និងលោក អ៊ួន សាកល ដែលបានទទួលការផ្ទេរសិទ្ធិពីអ្នកទាំង៥រូប ខាងលើបានបញ្ជាក់ថា ពួកគាត់ទាំង ៥រូប មិនបានប្រព្រឹត្តដូចការចោទប្រកាន់របស់លោក ហ៊ីង យឿន ទេ គឺពួកគាត់ចុះទៅទីតាំងការិយាល័យ បោះឆ្នោតមណ្ឌលវត្តភ្នំដំរីចាំយាមមើលសភាពការណ៍សន្តិសុខនៅការិយាល័យបោះឆ្នោតតាមកំណត់ក្នុងចំណាត់ការលេខ ២៩៨/១២ ដក/ខជ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ របស់អនុគណៈកម្មការសន្តិសុខឃុំដំណាក់កន្ទួតខាងជើង ។ អ្នកទាំង៥រូបនេះគ្រាន់តែបានជួយសម្រួល និងផ្តល់ព័ត៌មានអំពីទីតាំងការិយាល័យបោះឆ្នោត ជូនអ្នកបោះឆ្នោតដែលមកសាកសួរតែប៉ុណ្ណោះ ។ នៅក្នុងសវនាការលោកស្រី អ៊ិត គីហ៊ូប៉ាតី និងលោក អ៊ួន សាកល មានសាក្សីចំនួន ២រូប បញ្ជាក់អំពីព្រឹត្តិការណ៍កាលពីថ្ងៃទី៣ ខែមិថុនា នៅមណ្ឌលបោះឆ្នោតវត្តភ្នំដំរីជូនដល់អង្គសវនាការទាំងមូល ។ ឈ្មោះ ប៉ិល មិត្ត និងឈ្មោះ ប៉ាំង លុច ដែលជាសាក្សីបានរៀបរាប់ស្រដៀងគ្នាថា ខ្លួនបានទៅបោះឆ្នោតនៅការិយាល័យនៃមណ្ឌលបោះឆ្នោតខាងលើនេះ ប៉ុន្តែគាត់មិនចេះអក្សររកការិយាល័យបោះឆ្នោតមិនឃើញ ក៏បានយកឯកសារបោះឆ្នោតទៅសួរលោកមេភូមិឈ្មោះ គង់ សំ ដែលកំពុងឈរនៅលើវិហារវត្ត ពេលនោះឈ្មោះ គង់ សំ ក៏បានចង្អុលប្រាប់ទីតាំងការិយាល័យបោះឆ្នោតរបស់គាត់ ។

លោកមេភូមិពុំបាននិយាយអ្វី ឬក៏កត់ឈ្មោះគាត់ចូលទៅក្នុងសៀវភៅទេ ។

ក្រោយពីបានស្តាប់ដើមបណ្តឹង ចុងចម្លើយ និងបានពិនិត្យពិចារណាលើអង្គហេតុរួចមក ក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា ឈ្មោះ គង់ សំ ឈ្មោះ ញឹម ផា ឈ្មោះ ឌួក ឌន ឈ្មោះ ង៉ែត ហួន និងឈ្មោះ ផេង សាលី អនុវត្តខុសភារកិច្ច ដែលបានកំណត់ក្នុងចំណាត់ការលេខ ២៩៨/១២ ជក/ខជ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ និងខុសពីបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ។ ដូចនេះក្រុមប្រឹក្សាជំនុំជម្រះបានសម្រេចបញ្ជូនឈ្មោះអ្នកទាំង៥រូប ទៅក្រសួងមហាផ្ទៃ ដើម្បីធ្វើការព្រមានតាមច្បាប់ និងបដិសេធសេចក្តីសម្រេចលេខ ១២៤ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១២ របស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តកំពត(គខប) ចោលជាអសាបង់ ។ សេចក្តីសម្រេចនេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅចំពោះមុខដើមបណ្តឹង និងចុងចម្លើយ នាថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២ និងជាសេចក្តីសម្រេចចុងក្រោយ ។

សូមរំលឹកថា បណ្តឹងខាងលើនេះត្រូវបានតំណាងគណបក្ស សម រង្ស៊ីប្តឹងទៅ គខប កំពត កាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១២ ។ ករណីនេះត្រូវបាន គខប កំពត បើកសវនាការនៅថ្ងៃទី៨ ខែមិថុនា បដិសេធបណ្តឹងចោល ដោយសារការឆ្លើយបំភ្លឺរវាងដើមបណ្តឹង និងចុងចម្លើយមានភាពផ្ទុយគ្នា ហើយម្យ៉ាងទៀតដំណើរការបោះឆ្នោតបានប្រព្រឹត្តទៅដោយប្រក្រតីរហូតដល់ចប់ ។

***សវនាការលើកទី៣*** : ជំនុំជម្រះបណ្តឹងរបស់គណបក្ស សម រង្ស៊ី ដែលបានប្តឹងបដិសេធចោលលទ្ធផលបោះឆ្នោតសង្កាត់ទួលសង្កែ និងសុំឲ្យមានការរៀបចំការបោះឆ្នោតនៅសង្កាត់នេះសាជាថ្មី ។ ខ្លឹមសារនៃការជំនុំជម្រះមានដូចតទៅ ៖

កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១២ បណ្តឹងរបស់លោក គឹម ណារុន តំណាងគណបក្ស សម រង្ស៊ី ដែលបានប្តឹងបដិសេធចោលលទ្ធផលបោះឆ្នោតសង្កាត់ទួលសង្កែ និងសុំឱ្យមានការរៀបចំការបោះឆ្នោតនៅសង្កាត់នេះសាជាថ្មី ត្រូវបានក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប បានជំនុំជម្រះ និងប្រកាសជាសាធារណៈសម្រេចបដិសេធចោល ។

បណ្តឹងខាងលើនេះ ត្រូវបានតំណាងគណបក្ស សម រង្ស៊ី ដាក់ពាក្យបណ្តឹងទៅ គជប រាជធានីភ្នំពេញ កាលពី ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ហើយត្រូវបាន គជប រាជធានីភ្នំពេញ ប្រជុំសម្រេចកាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១២ ដោយបដិសេធបណ្តឹងនេះចោល ។ ដោយមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ គជប រាជធានីភ្នំពេញ លោក គឹម ណារុន បានដាក់ពាក្យបណ្តឹងបន្តមក គ.ជ.ប កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១២ ។



លោក គឹម ណារុន តំណាងគណបក្ស សម រង្ស៊ី

នៅក្នុងសវនាការ លោក គឹម ណារុន បានថ្លែងថា ដំណើរការនៃការបោះឆ្នោតនៅក្នុងសង្កាត់ទួលសង្កែមានភាពមិនប្រក្រតីកើតឡើង ដូចជា ការិយាល័យបោះឆ្នោតក្នុងមណ្ឌលបឋមសិក្សាទួលសង្កែចំនួន ៥ការិយាល័យ មានតុ និងកៅអីគរនៅមាត់បង្អួច ពុំមានលក្ខណៈចំហរ មានអ្នកបោះឆ្នោតយកប័ណ្ណគណបក្សប្រជាជនកម្ពុជាទៅបោះឆ្នោត និងមានអ្នកបោះឆ្នោតចំនួន ២នាក់ដែលឈ្មោះខ្លួនត្រូវបានគេបោះឆ្នោតរួចហើយ ថែមទាំងមានការគំរាមកំហែងដល់ភ្នាក់ងារគណបក្ស សម រង្ស៊ី។

លោកបានបន្ថែមទៀតថា លោកមានភស្តុតាង សាក្សី និងឯកសាររូបថតជាសំអាង ដើម្បីឱ្យក្រុមប្រឹក្សាជំនុំជម្រះធ្វើការពិចារណា ។

ឆ្លើយតបទៅនឹងការលើកឡើងរបស់គណបក្ស សម រង្ស៊ី លោក ស៊ុន ពិសិដ្ឋ អតីតប្រធានការិយាល័យបោះឆ្នោតលេខ ០៧២៣ បានបញ្ជាក់ថា ការិយាល័យបោះឆ្នោតរបស់លោក ពុំមានអ្នកបោះឆ្នោតណាម្នាក់យកប័ណ្ណគណបក្សប្រជាជនកម្ពុជាចូលទៅបោះឆ្នោតនោះឡើយ ហើយក៏ពុំមានការតវ៉ា ឬជំទាស់ពីភ្នាក់ងារ



លោក ស៊ុន ពិសិដ្ឋ អតីតប្រធានការិយាល័យបោះឆ្នោតលេខ ០៧២៣

គណបក្សនយោបាយណាមួយ នៅពេលបោះឆ្នោតនោះដែរ ។ រីឯបញ្ហាដែលមានអ្នកបោះឆ្នោតត្រូវបានគេបោះឆ្នោតជំនួសក៏គ្មានដែរ ។



លោកស្រី លឹម គុណសុទ្ធី អតីតប្រធានការិយាល័យបោះឆ្នោតលេខ ០៧៣៣

នៅក្នុងសវនាការនោះ លោកស្រី លឹម គុណសុទ្ធី



ឯកឧត្តម អ៊ឹម សួស្តី លោកជំទាវបណ្ឌិត ស៊ីន ជុំបូ(រូបឆ្វេង) និងលោកជំទាវ កុយ វ៉ាត សមាជិកក្រុមប្រឹក្សាជំនុំជម្រះ គ.ជ.ប

អតីតប្រធានការិយាល័យបោះឆ្នោតលេខ ០៧៣៣ បានបញ្ជាក់ដែរថា នៅពេលបោះឆ្នោតកាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១២ ពុំមានការគំរាមកំហែងដូចការលើកឡើងរបស់តំណាងគណបក្ស សម រង្ស៊ី ទេ ។ ផ្ទុយទៅវិញលោក ឈឹម សំអាត ដែលជាភ្នាក់ងារគណបក្ស សម រង្ស៊ី មិនបានគោរពតាមតួនាទីរបស់ខ្លួន លោកបញ្ជាទៅមន្ត្រីការិយាល័យបោះឆ្នោត ទើបលោកប្រធានគណៈកម្មការរៀបចំការបោះឆ្នោតសង្កាត់ទួលសង្កែ( គឃប) ប្រាប់អំពីក្រមសីលធម៌របស់ភ្នាក់ងារនៃគណបក្សនយោបាយ និងសំណូមពរឱ្យភ្នាក់ងារគណបក្ស សម រង្ស៊ី បញ្ឈប់ការបង្គាប់បញ្ជានៅក្នុងការិយាល័យបោះឆ្នោត បើមិនដូចនេះទេ គាត់នឹងហៅប៉ូលីសមកអញ្ជើញចេញក្រៅការិយាល័យ ។

ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹង និងពិនិត្យភស្តុតាងដែលមានក្នុងសំណុំរឿង ព្រមទាំងបានពិចារណាលើអង្គហេតុរួចមក ក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថាភស្តុតាងដែលដើមបណ្តឹងបានផ្តល់ជូនអំពីភាពមិនប្រក្រតីនៅការិយាល័យបោះឆ្នោត ដើម្បីសុំបដិសេធលទ្ធផលបោះឆ្នោត និងសុំបោះឆ្នោតសាជាថ្មី ពុំមានមូលដ្ឋានផ្លូវច្បាប់ ដែលតម្រូវឱ្យក្រុមប្រឹក្សាជំនុំជម្រះបដិសេធលទ្ធផលបោះឆ្នោត និងរៀបចំបោះឆ្នោតសាជា

ថ្មីនោះទេ ។ ដូចនេះ ក្រុមប្រឹក្សាជំនុំជម្រះបានសម្រេចបដិសេធចោលបណ្តឹងរបស់លោក គឹម ណារុន ព្រោះផ្ទុយនឹងគតិច្បាប់ និងសម្រេចតម្កល់សេចក្តីសម្រេចរបស់ គធប រាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល ហើយសេចក្តីសម្រេចនេះជាសេចក្តីសម្រេចចុងក្រោយ។

***សវនាការលើកទី៤*** : ជំនុំជម្រះបណ្តឹងរបស់គណបក្ស សម រង្ស៊ី ដែលបានប្តឹងបដិសេធសេចក្តីសម្រេចរបស់ គធប រាជធានីភ្នំពេញ ដែលបានពិន័យលោក សម រង្ស៊ី ចំនួន ១០លានរៀល និងបណ្តឹងរបស់គណបក្សប្រជាជនកម្ពុជា ដែលបានប្តឹងបដិសេធសេចក្តីសម្រេចរបស់ គធប រាជធានីភ្នំពេញ ពីព្រោះការពិន័យលោក សម រង្ស៊ី ចំនួន ១០លានរៀល មិនទាន់សមស្របទៅនឹងអំពើរបស់លោក សម រង្ស៊ី ។ ខ្លឹមសារនៃការជំនុំជម្រះមានដូចតទៅ ៖

កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១២ ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប បានសម្រេចតម្កល់សេចក្តីសម្រេចរបស់ គធប រាជធានីភ្នំពេញ ដែលពិន័យលោក សម រង្ស៊ី ប្រធានគណបក្ស សម រង្ស៊ី ចំនួន ១០លានរៀល ពីបទរំលោភច្បាប់ បទបញ្ជា និងនីតិវិធី និងក្រមសីលធម៌នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ នៅក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។

ទាក់ទងនឹងអង្គហេតុនៃបណ្តឹងខាងលើនេះ លោក ព្រហ្ម គន្ធ តំណាងគណបក្សប្រជាជនកម្ពុជា (ដើមបណ្តឹង) បានលើកឡើងថា កាលពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១២ ដែលជាថ្ងៃចុងក្រោយនៃការឃោសនាបោះឆ្នោត គណបក្ស សម រង្ស៊ី បានធ្វើការឃោសនាតាមរយៈវីដេអូខនហ្វើរិន (Conference) ដែលថ្លែងដោយលោក សម រង្ស៊ី បានប្រើពាក្យបរិហារកេរ្តិ៍ ប្រមាថជាសាធារណៈទៅលើសម្តេចនាយករដ្ឋមន្ត្រី ដោយប្រើពាក្យ "***រដ្ឋាភិបាលក្បត់ជាតិ រដ្ឋាភិបាល ហ៊ុន សែន***" ។ លោក បានបន្តថា ការថ្លែងបែបនេះបានរំលោភច្បាប់ បទបញ្ជា និងនីតិវិធី និងក្រមសីលធម៌នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ។

ករណីនេះត្រូវបានលោក ព្រហ្ម គន្ធ ដាក់ពាក្យបណ្តឹងទៅ គធប រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២ ហើយ គធប រាជធានីភ្នំពេញ បានបើកសវនាការនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ ដោយសម្រេចផ្តន្ទាទោសលោក សម រង្ស៊ី ពិន័យជាប្រាក់ចំនួន ១០លានរៀល ។ ប៉ុន្តែលោកមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ គធប រាជធានីភ្នំពេញទេ ពីព្រោះការពិន័យនេះមិនទាន់សមស្របទៅនឹងអំពើរបស់លោក សម រង្ស៊ី និងគណបក្ស សម រង្ស៊ី ដែលបានជេរប្រមាថ បរិហារកេរ្តិ៍ជាសាធារណៈ មួលបង្កាច់បង្ខូចឈ្មោះរដ្ឋាភិបាល ទើបលោកប្តឹងតវ៉ាមក គ.ជ.ប ជាបន្តទៀត។

ទាក់ទងនឹងសំណុំរឿងនេះដែរ លោក ថាច់ យុនសារិន តំណាងគណបក្ស សម រង្ស៊ី បានដាក់ពាក្យបណ្តឹងនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២ មក គ.ជ.ប បដិសេធសេចក្តីសម្រេចរបស់ គធប រាជធានីភ្នំពេញ ដែលបានពិន័យលោក សម រង្ស៊ី ចំនួន ១០លានរៀល ។

ដោយយល់ឃើញថា សំណុំរឿងទាំង ២ខាងលើនេះមានអង្គហេតុដូចគ្នា ក្រុមប្រឹក្សាជំនុំជម្រះបានសម្រេចបញ្ចូលសំណុំរឿងនេះជារឿងតែមួយ (លេខ០៤៥/១២)។ ហើយក្រោយពីបានស្តាប់ដើមបណ្តឹង ចុងចម្លើយ និងបានពិនិត្យពិចារណាលើអង្គហេតុរួចមក ក្រុមប្រឹក្សាជំនុំជម្រះបានសម្រេចបដិសេធចោលបណ្តឹងរបស់លោក ព្រហ្ម គន្ធ និងបណ្តឹងរបស់លោក ថាច់ យុនសារិន ព្រោះផ្ទុយនឹងគតិច្បាប់ ។ តម្កល់សេចក្តីសម្រេចលេខ ០០១/១២ គធប.ស.ស.រ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ របស់ គធប រាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល ។ សេចក្តីសម្រេចនេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈនៅចំពោះគូភាគី និងជាសេចក្តីសម្រេចចុងក្រោយ ។/

# សន្និបាតបូកសរុបការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ នៅខេត្តព្រៃវែង និងខេត្តមណ្ឌលគិរី

កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១២ គណៈកម្មការរៀបចំការបោះឆ្នោតខេត្តព្រៃវែង(គខប) បានរៀបចំពិធីសន្និបាតបូកសរុបការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ដើម្បីដកស្រង់បទពិសោធន៍រកចំណុចខ្លាំង ចំណុចខ្សោយ និងលើកជាសំណូមពរ ដើម្បីឲ្យការបោះឆ្នោតខាងមុខកាន់តែប្រសើរឡើងថែមទៀត ។



លោក ហួត ផាន ប្រធាន គខប ព្រៃវែង

សន្និបាតនេះបានប្រព្រឹត្តទៅនៅក្នុងក្លឹបកីឡាដ្ឋានខេត្ត ដែលមានអ្នកចូលរួមជាតំណាងអភិបាលខេត្ត នគរបាលខេត្ត តំណាងមេបញ្ជាការកងរាជអាវុធហត្ថខេត្ត មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងខេត្ត មន្ត្រី គខប អភិបាលនៃគណៈអភិបាលស្រុក ក្រុងទូទាំងខេត្ត មេឃុំ ចៅសង្កាត់ទូទាំងខេត្ត ប្រធានគណៈកម្មការរៀបចំការបោះឆ្នោតឃុំ សង្កាត់ ទូទាំងខេត្ត តំណាងគណបក្សនយោបាយ តំណាងអង្គការមិនមែនរដ្ឋាភិបាលសរុបចំនួន ២៦៧នាក់ ។

លោក ហួត ផាន ប្រធាន គខប ព្រៃវែង បានមានប្រសាសន៍ថា សន្និបាតបូកសរុបការងារនេះបានផ្តោតលើប្រធានបទចំនួន ៣រួមមាន៖ ទី១ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ទី២ ការឃោសនាបោះឆ្នោត និងទី៣ ការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដើម្បីឱ្យអ្នកចូលរួមបញ្ចេញមតិយោបល់ ផ្លាស់ប្តូរបទពិសោធន៍នានា សំដៅឈានទៅកែលម្អនៅពេលបោះឆ្នោតខាងមុខទៀត ។

លោកបានបញ្ជាក់ថា អនុសាសន៍ និងសំណូមពរដែលអស់លោក លោកស្រីបានលើកឡើងក្នុងពេលនេះ គឺជាគំនិតផ្តួចផ្តើមដ៏ល្អៗ ដែលត្រូវកត់ត្រាលើកយកទៅរាយការណ៍ជូនក្នុងសន្និបាតថ្នាក់ជាតិ(គ.ជ.ប) ដើម្បីឱ្យមានការសម្របសម្រួលកែតម្រូវយ៉ាងណាៗ ដូចជា ករណី



កែលម្អបច្ចេកទេស បែបបទ និងនីតិវិធីនៃការរៀបចំបញ្ជីឈ្មោះបោះឆ្នោត ការអប់រំ និងការផ្សព្វផ្សាយព័ត៌មានដល់អ្នកបោះឆ្នោត ការលើកកម្ពស់សមត្ថភាពយល់ដឹងរបស់មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការជម្រុញ និងលើកទឹកចិត្តដល់មេឃុំ ចៅសង្កាត់ និងស្មៀនក្នុងការអនុវត្តភារកិច្ចដែល គ.ជ.ប បានធ្វើប្រតិភូកម្មអំណាចឱ្យ កិច្ចសហការជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិក្នុង

ការរក្សាស្ថិរភាព សន្តិសុខ សណ្តាប់ធ្នាប់ក្នុងដំណើរការបោះឆ្នោត ពង្រឹងទំនាក់ទំនងល្អជាមួយ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបង្កលក្ខណៈងាយស្រួលដល់គ្រប់ភាគីពាក់ព័ន្ធនឹងការបោះឆ្នោត ។

សន្និបាតបូកសរុបការងារដូចគ្នានេះដែរ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី២៣ ខែមិថុនា នៅគណៈកម្មការរៀបចំការបោះឆ្នោតខេត្តមណ្ឌលគិរី(គខប) នាសាលប្រជុំក្រុមប្រឹក្សាខេត្ត ដែលមានការអញ្ជើញចូលរួមពី



ពិធីសន្និបាតបូកសរុបការងារនៅ គខប មណ្ឌលគិរី



សំណាក់ឯកឧត្តម សមាជិកក្រុមប្រឹក្សាខេត្ត ឯកឧត្តមអភិបាលខេត្ត មន្ត្រី បុគ្គលិក តំណាងអាជ្ញាធរខេត្ត តំណាងកងកម្លាំងប្រដាប់អាវុធទាំង ៣ប្រភេទ ប្រធានក្រុមប្រឹក្សាក្រុង ស្រុក អភិបាលក្រុង ស្រុក តំណាងគណបក្សនយោបាយ តំណាងអង្គការមិនមែនរដ្ឋាភិបាល ប្រធាន គឃ/សប មេឃុំ ចៅសង្កាត់ សរុបប្រមាណ ៨៩នាក់ ក្នុងនោះស្រីចំនួន ១៣នាក់ ។

អង្គសន្និបាតបានធ្វើការពិភាក្សារកចំណុចខ្លាំង និងចំណុចខ្សោយ ការលំបាក និងលើកជាសំណូមពរមួយចំនួន ដើម្បីដាក់ជូននៅក្នុងអង្គសន្និបាតថ្នាក់ជាតិ (គ.ជ.ប) ។



ពិធីប្រគល់លិខិតសរសើរ និងលិខិតបញ្ជាក់ ជូនគណៈបញ្ជាការឯកភាពខេត្ត


## ក្រុមរៀបចំព្រឹត្តិបត្រព័ត៌មាន គ.ជ.ប

**អ្នកគ្រប់គ្រង**

លោក មៃ សារី

**ក្រុមនិពន្ធ**

លោក មិន ពុធជេដ្ឋាវណ្ណ លោក សុខ លាត

លោក ទិន ករុណា

**កំណែអក្ខរាវិរុទ្ធ**

អ្នកស្រី ទិន សារត្តី

**អ្នកថតរូប**

លោក សាក់ ប៉ូរិន លោក គឹម យុង

លោក រិន វុទ្ធី

**ក្រាហ្វិកកុំព្យូទ័រ**

លោក ប៉េង រតនៈ លោក ចាន់ វិបុល

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១២

## ប្រតិទិននៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១២

## ( វិសោធនកម្ម )

| ភារកិច្ចត្រូវបំពេញ | កាលបរិច្ឆេទ |
|---|---|
| ការចុះឈ្មោះអ្នកសង្កេតការណ៍ | ថ្ងៃទី ១៦ ខែ សីហា - ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១២ |
| ការចុះឈ្មោះតំណាងគណបក្សនយោបាយ | ថ្ងៃទី ២៣ ខែ សីហា - ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១២ |
| ការបិទផ្សាយបញ្ជីទីតាំងការិយាល័យបោះឆ្នោត និងទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត | ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១២ |
| ការបិទផ្សាយបញ្ជីបោះឆ្នោតចុងក្រោយ (បញ្ជីបោះឆ្នោតឆ្នាំ២០១១) នៅសាលាឃុំ សង្កាត់ | ថ្ងៃទី ៣០-៣១ ខែ សីហា ឆ្នាំ ២០១២ |
| ការចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនៅតាមឃុំ សង្កាត់ | ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១២ |
| ការបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនៅតាមឃុំ សង្កាត់ | ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១២ |
| ការប្តឹងតវ៉ានឹងការបដិសេធការសុំចុះឈ្មោះទៅក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរយៈពេល ០៣ថ្ងៃ | ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១២ ( **ថ្ងៃចុងក្រោយ** ) |
| ការដោះស្រាយបណ្តឹងតវ៉ាដោយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ០៣ថ្ងៃ | ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១២ ( **ថ្ងៃចុងក្រោយ** ) |
| ការប្តឹងតវ៉ានឹងការបដិសេធរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ទៅ គ.ជ.ប ក្នុងរយៈពេល ០៥ថ្ងៃ | ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១២ ( **ថ្ងៃចុងក្រោយ** ) |
| ការដោះស្រាយបណ្តឹងតវ៉ាដោយ គ.ជ.ប ក្នុងរយៈពេល ០៥ថ្ងៃ | ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១២ ( **ថ្ងៃចុងក្រោយ** ) |
| ការប្តឹងតវ៉ានឹងការបដិសេធរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ០៥ថ្ងៃ | ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១២ ( **ថ្ងៃចុងក្រោយ** ) |
| ការដោះស្រាយបណ្តឹងដោយក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ១០ថ្ងៃ | ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ ( **ថ្ងៃចុងក្រោយ** ) |
| ការបិទផ្សាយព្រមព្រាងបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ ដែលគ្មានបណ្តឹងតវ៉ា | ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ |
| ការប្តឹងតវ៉ា ឬជំទាស់លើបញ្ជីបោះឆ្នោតដំបូងទៅក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរយៈពេល ១០ថ្ងៃ | ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១២ ( **ថ្ងៃចុងក្រោយ** ) |
| ការដោះស្រាយបណ្តឹងដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរយៈពេល ០៣ថ្ងៃ | ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ( **ថ្ងៃចុងក្រោយ** ) |
| ការប្តឹងតវ៉ា ឬជំទាស់នឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ទៅ គ.ជ.ប ក្នុងរយៈពេល ០៥ថ្ងៃ | ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ ( **ថ្ងៃចុងក្រោយ** ) |
| ការដោះស្រាយបណ្តឹងដោយ គ.ជ.ប ក្នុងរយៈពេល ០៥ថ្ងៃ | ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១២ ( **ថ្ងៃចុងក្រោយ** ) |
| ការប្តឹងតវ៉ា ឬជំទាស់នឹងសេចក្តីសម្រេចរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ០៥ថ្ងៃ | ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១២ ( **ថ្ងៃចុងក្រោយ** ) |
| ការដោះស្រាយបណ្តឹងដោយក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ១០ថ្ងៃ | ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១២ ( **ថ្ងៃចុងក្រោយ** ) |
| ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ ដែលមានបណ្តឹងតវ៉ា | ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១២ ( **ថ្ងៃចុងក្រោយ** ) |
| ដំណើរការដាក់ និងដោះស្រាយបណ្តឹងលើបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ មានបណ្តឹង | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១២ ( **ថ្ងៃចុងក្រោយ** ) |
| ការផ្តល់សុពលភាព និងប្រកាសផ្សាយបញ្ជីបោះឆ្នោតឆ្នាំ២០១២ ដោយ គ.ជ.ប | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១២ |

# ពិធីសន្និបាតបូកសរុបការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣
# នៅខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តស្វាយរៀង

## ● ពិធីសន្និបាតបូកសរុបការងារនៅគណៈកម្មការរៀបចំការបោះឆ្នោតខេត្តកំពង់ឆ្នាំង





## ● ពិធីសន្និបាតបូកសរុបការងារនៅគណៈកម្មការរៀបចំការបោះឆ្នោតខេត្តពោធិ៍សាត់





## ● ពិធីសន្និបាតបូកសរុបការងារនៅគណៈកម្មការរៀបចំការបោះឆ្នោតខេត្តស្វាយរៀង





សន្និបាតបូកសរុបការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣
នឹងប្រព្រឹត្តទៅនៅថ្ងៃទី១២-១៣ ខែកក្កដា ឆ្នាំ២០១២